**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេស
ក្នុងកិច្ចប្រជុំពិគ្រោះយោបល់អំពីជំងឺគ្រុនចាញ់ ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៤

ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤
សណ្ឋាគារ ភ្នំពេញ

- លោកវេជ្ជបណ្ឌិត Dong-Il Ahn អ្នកតំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា និង ជាអនុប្រធាន CCC
- លោកវេជ្ជបណ្ឌិត ហ៊ុយ រ៉េកុល នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសមាជិក សមាជិកា អង្គប្រជុំទាំងអស់

ជាបឋមតាងនាមគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមនៅក្នុងអង្គប្រជុំដ៏មានសារៈសំខាន់នាពេលនេះ ដើម្បីរៀបចំចងក្រងឯកសារកំណត់បង្ហាញទស្សនៈអំពីជំងឺគ្រុនចាញ់ (Malaria Concept Note) តាមគំរូហិរញ្ញប្បទានថ្មីរបស់មូលនិធិសកល ។ ថ្ងៃនេះយើងជួបជុំគ្នា ដើម្បីពិគ្រោះយោបល់អំពីជំងឺ គ្រុនចាញ់ ដែលជាកិច្ចសន្ទនាប្រចាំប្រទេសកម្ពុជាឆ្នាំ២០១៤ រកឱ្យឃើញអា ទិភាវូបនីយកម្មសកម្មភាពសម្រាប់កំណត់បង្ហាញទស្សនៈ ។ ក្រុមការងារចំនួន ៦ ដែលនឹងត្រូវបង្កើតឡើងដើម្បីពិភាក្សាលើសេចក្តីព្រាងកំណត់បង្ហាញទស្សនៈនឹងត្រូវពិគ្រោះគ្នាអំពី ៖ ១ ក) ការធ្វើរោគវិនិច្ឆ័យជំងឺគ្រុនចាញ់

ពីដំបូង និងសេវាកម្មព្យាបាល ៖ ចូលទៅកៀកប្រជាជនដែលចល័ត បម្លាស់ទី និង ជនជាតិដើមភាគតិច ១ខ) កែលម្អសេវាជំងឺគ្រុនចាញ់ សម្រាប់ប្រជាជនទូទៅក្នុងតំបន់ដែលមានជំងឺ ២) ការលើកឡើងពីការប្រឆាំង ការបង្កាការព្យាបាលទោល/ឱសថក្រោមស្តង់ដារ ៣) ការកែលម្អការទទួលបានវិធានការបង្កា (មុង, ការបាញ់ថ្នាំនៅក្នុងលំនៅដ្ឋាន) ការកំណត់គោលដៅប្រសើរជាងមុន ៤) ការយល់ដឹងពីសហគមន៍ និង ការផ្លាស់ប្តូរអាកប្បកិរិយា (ការប្រាស្រ័យទាក់ទងដែលនាំឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា, ចលនាសហគមន៍ ការគាំទ្រ) ៥) សេវាគ្រប់គ្រងជំងឺគ្រុនចាញ់ប្រកបដោយប្រសិទ្ធភាព (ប្រព័ន្ធព័ត៌មាន + ការអនុវត្ត) + ការសម្របសម្រួល។

យើងមានភាពងាយស្រួលដោយ កំណត់បង្ហាញទស្សនៈជំងឺរបេងត្រូវបានអនុម័តរួចរាល់ហើយដែលអាចផ្តល់ជាបទពិសោធន៍សម្រាប់ជំងឺគ្រុនចាញ់ ។ ដូច្នេះ ខ្ញុំជឿជាក់ថាកំណត់បង្ហាញទស្សនៈជំងឺគ្រុនចាញ់ពេញលេញមួយនឹងដាក់ស្នើទៅ មូលនិធិសកល ឱ្យបានមុនថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ អាចនឹងសម្រេចបាន ។

ក្នុងគំរូហិរញ្ញប្បទានថ្មី មានសមាសធាតុសំខាន់ពីរដែលជាប់ពាក់ព័ន្ធនឹងការរៀបចំកំណត់បង្ហាញទស្សនៈ ៖ ១) ការរៀបចំតាក់តែងនូវសំណើបច្ចេកទសមួយដោយផ្អែកលើមូលដ្ឋានផែនការយុទ្ធសាស្ត្រជាតិ និង ២) ដំណើរការកិច្ចសន្ទនាប្រចាំប្រទេសដែលអនុញ្ញាតឱ្យដៃគូពហុភាព អ្នកពាក់ព័ន្ធ និង អ្នកនៅតាមមូលដ្ឋានផ្តល់នូវធាតុចូលរបស់ពួកគេក្នុងការតាក់តែងកម្មវិធីចុងក្រោយ និង សកម្មភាពអា ទិភាវូបនីយកម្ម ។ មេរៀនដែលបានរៀនសូត្រពីការរៀបចំកំណត់បង្ហាញទស្សនៈមាន ៖

១) ផ្តោតការយកចិត្តទុកដាក់លើអន្តរាគមន៍ចំពោះប្រជាជនជាគន្លឹះ

២) ផ្តោតការយកចិត្តទុកដាក់លើនិរន្តរភាព

៣) ធានានូវកិច្ចសន្ទនាដែលផុលផុសជុំវិញការបំបែកកម្មវិធី

៤) កែលម្អគុណភាពកំណត់បង្ហាញទស្សនៈ

៥) ធ្វើអាទិភាពអន្តរាគមន៍នានាដើម្បីទទួលបានការប៉ះទង្គិចធំធេងបំផុត

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា*

ខ្ញុំសង្ឃឹមថាការប្រជុំពិភាក្សារយៈពេលពីរថ្ងៃដែលយើងកំពុងធ្វើនេះ នឹងផ្តល់ជាលទ្ធផលដែលនាំឱ្យយើងរៀបចំបាននូវ កំណត់បង្ហាញទស្សនៈអំពីជំងឺ គ្រុនចាញ់ដ៏សមស្រប

ដើម្បីធានានូវការទទួលបានហិរញ្ញប្បទានពីមូលនិធិសកល ក្នុងការប្រយុទ្ធនឹងជំងឺ គ្រុនចាញ់ សម្រាប់រយៈពេល ៣ឆ្នាំខាងមុខ ។

ខ្ញុំជឿជាក់ថាតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ថ្ងៃនេះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ នឹងផ្តល់នូវធាតុចូលដ៏មានសារៈសំខាន់ដើម្បីរួមចំណែក ក្នុងការប្រយុទ្ធនឹងជំងឺដ៏កំណាចនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និង អ្នកចូលរួមទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និង ប្រាជ្ញាឈ្លៀសវៃ និង ជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងសូមកោតសរសើរផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ និង គណៈកម្មការរៀបចំអង្គពិធី ដែលបានរួមចំណែកធ្វើឱ្យសិក្ខាសាលាដ៏សំខាន់នេះអាចប្រព្រឹត្តទៅបាន ។

ខ្ញុំសូមប្រកាសបើក កិច្ចប្រជុំពិគ្រោះយោបល់អំពីជំងឺ គ្រុនចាញ់ ៖ កិច្ចសន្ទនាប្រចាំប្រទេសឆ្នាំ២០១៤ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*